សូមអរគុណចំពោះការចាប់អារម្មណ៍របស់អ្នកក្នុងការប្រលងគូរូបនិមិត្តសញ្ញា PCAT! នៅពេលដែលយើងបន្តស្តាប់សហាគមន៍និងរិះរកវិធីដើម្បីបំពេញតំរូវការរបស់អ្នករស់នៅក្នុងតំបន់ឌូវ៉មមីស
យើងបានសម្គាល់ឃើញនូវតំរូវការក្នុងការបង្កើតអ្វីមួយដែលអាចជួយអោយយើងងាយស្រួលនិងកាន់តែស្គាល់អត្តសញ្ញាណរបស់យើង។

នោះគឺជានិមិត្តសញ្ញាមួយ!
យើងសូមអញ្ជើញអ្នកឱ្យចូលរួមដោយបញ្ជូនការរចនានិមិត្តសញ្ញារបស់អ្នកជាអត្ថបទ
ដើម្បីតំណាងក្រុមសកម្មភាពសហាគមន៍កំពង់ផែ Port Community Action Team ។

## <u>តើ **PCAT** គឺជានរណា ?</u>

ក្រុម Port Community Action Team (PCAT)
គឺជាក្រុមប្រឹក្សាសហាគមន៍មួយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៧
និងមានសមាជិកសហាគមន៍មកពីតំបន់ឌូវ៉មមីសចូលរួមសហាការគ្នាធ្វើកិច្ចការនៅកំពង់ផែនិងផែនការយុទ្ធសាស្ត្រដើម្បីដោះស្រាយផលប៉ះពាល់ដែលធ្លាប់មានភាពមិនស្មើគ្នាពីអតីតកាលនិងបច្ចុប្បន្ននិងភាពប៉ះពាល់តៗគ្នាដែលប៉ះទង្គិចដល់សហាគមន៍ក្នុងតំបន់ឌូវ៉មមីស ។

បច្ចុប្បន្ននេះ ក្រុម PCAT កំពុងទាមទាររកការវិនិយោគ
អោយមានគម្រោងកម្មវិធីនិងគោលនយោបាយនានាដែលជួយបណ្តុះបណ្តាលសមត្ថភាពសហាគមន៍
បរិស្ថានសុខភាពនិងសហាគមន៍ហើយនិងការរីកចម្រើនផ្នែកសេដ្ឋកិច្ច។
យើងស្វែងរកការសហាការយ៉ាងសកម្មជាមួយអ្នកដែលរស់នៅ
ធ្វើការនិងគោរពបូជានៅតំបន់ឌូវ៉មមីសដើម្បីកំណត់អាទិភាពសម្រាប់ការងារទាំងនេះ ។

## <u>ការប្រលងគូរូបនិមិត្តសញ្ញា</u>

យើងកំពុងស្វែងរកជំនួយរបស់អ្នកក្នុងការរចនារូបនិមិត្តសញ្ញាដែលឆ្លុះបញ្ចាំងពីក្រុម PCAT និងលក្ខណៈនៃតំបន់ឌូវ៉មមីស។
សមាជិកសហាគមន៍ឌូវ៉មមីសត្រូវបានគេអញ្ជើញអោយបញ្ចូនទស្សនរចនារូបនិមិត្តសញ្ញារបស់ពួកគេយកមកប្រកួតប្រជែង។ ក្រុមការងារ PCAT
នឹងពិនិត្យនូវគោលគំនិតនិងជ្រើសរើសបេក្ខជន ៣ នាក់ចុងក្រោយ។
អ្នកចូលរួមប្រកួតប្រជែងទាំងនេះនឹងត្រូវបានអញ្ជើញអោយរចនារូបនិមិត្តសញ្ញាចុងក្រោយដើម្បីអោយសហាគមន៍ទាំងមូលបោះឆ្នោតជ្រើសរើស!

ចំណាត់ថ្នាក់ទី១ $1000
ចំណាត់ថ្នាក់ទី២ $500
ចំណាត់ថ្នាក់ទី៣ $250

ច្បាប់ប្រកួតប្រជែង
ម្នាក់ចុះឈ្មោះប្រកួតបានម្តង
អ្នកចូលរួមប្រកួតប្រជែងត្រូវរស់នៅ ធ្វើការ លេងកម្សាន្ត សិក្សា ហើយនិង/ឬគោរពបូជានៅជិតតំបន់កំពង់ផែក្បែរសៅផាក South Park និងជចថោន Georgetown ហើយនិងនៅតាមដងស្ទឹងឌូវ៉មមីស។
ការដាក់រូបប្រកួតមិនត្រូវល្មើសការរក្សាសិទ្ធិរបស់អ្នកដទៃ
ក្រុម PCAT រក្សាសិទ្ធិគ្រប់យ៉ាងលើគំនូរណាដែលឈ្នះរង្វាន់
ការដាក់ពាក្យប្រកួតអាចដាក់តាមបែបឌីជីថលឬដោយផ្ទាល់ដៃ (សូមទូរស័ព្ទទៅ (612) 470-1772 ឬអីមែលទៅ duwamishvalleypcat@gmail.com)

លក្ខណៈនៃការជ្រើសរើស
ក្រុម PCAT នឹងជ្រើសរើសបេក្ខជនចុងក្រោយដោយយោលទៅតាមរបៀបដែលគំនិតឆ្លុះបញ្ចាំងមានគោលបំណងនិងចក្ខុវិស័យរបស់ PCAT ។
យើងក៏នឹងស្វែងរកគំនិតច្នៃប្រឌិតនិងចក្ខុវិស័យ។
នេះគឺជាយោបល់មួយចំនួនដើម្បីជម្រុញនិងណែនាំពីការដាក់ពាក្យប្រកួតរបស់អ្នក៖
តំបន់អ្នករស់នៅ
សហាគមនិ
ស្ទឹង
ឧស្សាហាកម្ម
ដើមឈើ
ឫសឈើ
ស្ទឹងឌូវ៉មមីស
ទឹក
ផ្តល់ឥទ្ធិពលដល់អ្នកជិតខាងអោយធ្វើការរួមគ្នាជាមួយកំពង់ផែស៊ីឯថុល
ពហុភាសា
តំបន់រស់នៅដែលមានជាតិសាសចំរុះគ្នាច្រើន
ត្រីសាលមិន
ប្រវត្តិជនជាតិដើម
សាមគ្គី

<u>ពេលវេលាជ្រើសរើស</u>
ដើម្បីអោយមានអ្នកចូលរួមការប្រកួតនេះអោយបានកុះករ
ការប្រកួតនេះនឹងប្រព្រឹត្តឡើងជាច្រើនដំណាក់កាល។

ដំណាក់កាលទី១៖

ប្រជាជនរស់នៅក្នុងតំបន់ Duwamish Valley ត្រូវបានគេអញ្ជើញឱ្យដាក់ពាក្យចូលរួមប្រកួតមិនអោយហួសពី March 1st 2021។ ការចូលរួមដំបូងទាំងនេះអាចជាគំនិតសិន។ បន្ទាប់មកសមាជិកក្រុម PCAT នឹងបោះឆ្នោតជ្រើសរើសយក ៣ ដោយយោលទៅតាមលក្ខណៈវិនិច្ឆ័យខាងលើ។

ដំណាក់កាលទី២៖
អ្នកជាប់ចំណាត់ថ្នាក់ចុងក្រោយទាំង ៣ នឹងបន្តទំនាក់ទំនងជាមួយក្រុម PCAT ។ ពួកគេនឹងជួបជាមួយពួកយើង រៀនអំពីរឿងដើមកំណើតរបស់យើង ហើយនិងអំពីអ្វីដែលយើងសង្ឃឹមថានឹងបង្កើនឥទ្ធិពលសំលេងសហគមន៍របស់យើង។

បន្ទាប់មកបេក្ខជនចុងក្រោយនឹងត្រូវបានគេស្នើសុំឱ្យប្រែគំនិតរបស់គេចេញទៅជារូបនិមិត្តសញ្ញា ដោយកែសម្រួលរចនារបស់វាដោយយោលទៅតាមអន្តរកម្មជាមួយក្រុម PCAT ។

នៅពេលដែលពួកគេបញ្ចប់គំនូចុងក្រោយរបស់ខ្លួន ក្រុមការងារ PCAT នឹងអញ្ជើញសហគមន៍ឱ្យមកបោះឆ្នោតជ្រើសរើសនិមិត្តសញ្ញាដែលពួកគេពេញចិត្ត។ ការបោះឆ្នោតជ្រើសរើសរបស់សហគមន៍នឹងបិទនៅ April 15th 2021.

ដំណាក់កាលទី៣៖
ក្រុមការងារ PCAT នឹងរាប់សន្លឹកឆ្នោតដែលបោះដោយសហគមន៍។
នៅ May 1st 2021 យើងនឹងប្រកាសអ្នកឈ្នះនិងបង្ហាញរូបនិមិត្តសញ្ញាថ្មី!

សូមដាក់ពាក្យប្រកួតរបស់អ្នកនៅទីនេះ

**តើនរណាគឺជាក្រុមសកម្មភាពសហគមន៍កំពង់ផែ?**

ក្រុម Port Community Action Team (PCAT) គឺជាក្រុមប្រឹក្សាសហគមន៍មួយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៧ និងមានសមាជិកសហគមន៍មកពីតំបន់ឌូវ៉មមីសចូលរួមសហការគ្នាធ្វើកិច្ចការនៅកំពង់ផែនិងផែនការយុទ្ធសាស្ត្រដើម្បីដោះស្រាយផលប៉ះពាល់ដែលធ្លាប់មានភាពមិនស្មើគ្នាពីអតីតកាលនិងបច្ចុប្បន្ននិងភាពប៉ះពាល់តៗគ្នាដែលប៉ះទង្គិចដល់សហគមន៍ក្នុងតំបន់ឌូវ៉មមីស ។ បច្ចុប្បន្ននេះ ក្រុម PCAT កំពុងទាមទាររកការវិនិយោគ អោយមានគម្រោងកម្មវិធីនិងគោលនយោបាយនានាដែលជួយបណ្តុះបណ្តាលសមត្ថភាពសហគមន៍ បរិស្ថានសុខភាពនិងសហគមន៍ហើយនិងការរីកចម្រើនផ្នែកសេដ្ឋកិច្ច។ យើងស្វែងរកការសហការយ៉ាងសកម្មជាមួយអ្នកដែលរស់នៅ

ធ្វើការនិងគោរពបូជានៅតំបន់ឌូវ៉មមីសដើម្បីកំណត់អាទិភាពសម្រាប់ការងារទាំងនេះ ។

សាវតានិងប្រវត្តិ

ក្នុងឆ្នាំ ២០១៣ ក្រុមការងារ Just Health Action និងក្រុមប្រឹក្សាបច្ចេកទេសសម្អាតស្ទឹងឌូវ៉មមីស Duwamish បានចាប់ផ្តើមធ្វើការលើការវិភាគផលប៉ះពាល់សុខភាព (CIA) ។ ពួកគេក៏បានសន្និដ្ឋានថា "ការប៉ះពាល់សុខភាពនិងផលប៉ះពាល់ជាច្រើនទៀតបានប៉ះទង្គិចដល់ប្រជាជនរស់នៅតាមតំបន់ឌូវ៉មមីស ទីកន្លែងដ៏ធំដែលត្រូវបានប៉ះពាល់ខ្លាំងបំផុតដោយសាមានកាកសំណល់កខ្វក់ លក្ខណៈបរិស្ថានដែលបានសាងសង់មិនបានល្អហើយនិងមានសារជាតិពុលបរិយាកាសធ្ងន់ធ្ងរ បើប្រៀបធៀបទៅនឹងទីកន្លែងផ្សេងទៀតក្នុងទីក្រុង Seattle ។ អាយុកាលមធ្យមរបស់ប្រជាជនរស់នៅជចថោន Georgetown ហើយនិង សៅផាក South Park មានអាយុ ១៣ ឆ្នាំ ខ្លីជាងអ្នកដ៏ទៃទៀតដែលរស់នៅទីកន្លែងផ្សេងទៀតនៃទីក្រុង Seattle ។

សេចក្តីត្រូវការដោះស្រាយការរកឃើញទាំងនេះ បានបង្កើតគម្រោងសាកល្បងមួយរវាងកំពង់ផែហើយនិងក្រុម PCAT ហើយពួកគេក៏ផ្តោតលើការបង្កើតសេដ្ឋកិច្ចសម្រាប់សហាគមន៍ផងដែរ។

នៅតំបន់ឌូវ៉មមីស មានប្រជាជនឡាតាំង សូម៉ាលី ជនជាតិវៀតណាម ហើយនិងខ្មែរជាច្រើនរស់នៅទីនេះ ហើយវាជាតំបន់ដ៏ក្រីក្របំផុតមួយនៅក្នុងទីក្រុងស៊ីថុល។

ក្រុមសហាគមន៍មួយដែលបានចូលរួមធ្វើការងារគឺក្រុមយុវជនតំបន់ឌូវ៉មមីស។ ការចូលរួមរបស់យុវជនគឺជាសមាសធាតុសំខាន់មួយនៃគម្រោងការសាកល្បង។ ពួកគេត្រូវបានជ្រើសរើសដើម្បីជួយសំរួលសិក្ខាសាលាមួយចំនួនដែលត្រូវបានរៀបចំឡើងដើម្បីបង្កើតអោយមានភាពងាយស្រួលដល់ពួកគេចូលរួមក្នុងឯកម្មវិធីហាត់ហ្វឹកហ្វឺន បង្កើតប្រវត្តិធ្វើការងារ ហើយនិងការត្រៀមខ្លួនក្នុងការប្រកបអាជីពទៅអនាគត់។ ចាប់តាំងពីឆ្នាំ ២០១៨ មានយុវជនចំនួន ១៧ នាក់បានធ្វើការអោយកំពង់ផែនេះ។ លើសពីនេះទៅទៀត ក្រុម PCAT បានជួយជំរុញកិច្ចសហប្រតិបត្តិការគ្នា ក្នុងគម្រោងផ្លូវអាជីព ការសិក្សាផលប៉ះពាល់បរិស្ថានជាមួយសម្ព័ន្ធ Northwest Seaport Alliance និងគម្រោងពង្រឹងសហាគមន៍ដូចជាផ្ទែកសិល្ប: Duwamish River Mural Art.

នៅពេលដែលគម្រោងសាកល្បងជិតដល់ទីបញ្ចប់
កំពង់ផែក្រុងស៊ីងថុលហើយនិងក្រុម PCAT
បានព្យាយាមបន្តភាពជាដៃគូរបស់ខ្លួនតទៅទៀត។

នៅថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០១៩
ស្នងការកំពង់ផែបានអនុម័តជាឯកច្ឆន្ទនូវចលនាមួយដែលបង្កើតកម្មវិធីសមធម៌សហាគមន៍ប្រចាំតំបន់ឌូវ៉ាមមីស (DVCEP)
ដោយធ្វើកិច្ចសហការជាផ្លូវការរវាងសហាគមន៍កំពង់ផែក្រុងស៊ីងថុលនិងសហាគមន៍នានាក្នុងតំបន់ឌូវ៉ាមមីស។

នៅក្នុងខែបន្តបន្ទាប់មកទៀត ក្រុម PCAT និងកំពង់ផែ Seattle
នឹងចាប់ផ្តើមសហការគ្នាលើអ្វីដែលគេនឹងសន្យាធ្វើអោយក្លាយជាបានផលប្រយោជន៍សម្រាប់សហាគមន៍ក្នុងតំបន់ស្ទឹងឌូវ៉ាមមីស។

ក្រុមសហាគមន៍ក្នុងតំបន់ស្ទឹងឌូវ៉ាមមីស DVCBC
បានស្វែងរកបង្កើតក្របខ័ណ្ឌដើម្បីបន្តកិច្ចសហប្រតិបត្តិការតាមរយៈចំនួនបីចំណុចៈ

1. ការកសាងសងសមត្ថភាពក្នុងសហាគមន៍ - តើយើងប្រើប្រាស់និងចែករំលែកធនធានយ៉ាងដូចម្តេចដើម្បីឱ្យសហាគមន៍ទាំងអស់រីកចម្រើន? កំពង់ផែឆ្លងកាត់តាមរយៈស្ថាប័នរបស់ខ្លួននិងសហាគមន៍ក្នុងតំបន់ស្ទឹងឌូវ៉ាមមីស តាមរយៈការចំណែករបស់ខ្លួនក្នុងវិស័យវប្បធម៌និងឆ្លុះបញ្ចាំងសេដ្ឋកិច្ចនៃតំបន់នេះ?
2. សហាគមន៍និងបរិស្ថានដែលមានសុខភាពល្អ - តើយើងសហការគ្នាយ៉ាងដូចម្តេចដើម្បីធានាថាប្រជាជនដែលត្រូវរងផលប៉ះពាល់ច្រើនជាងគេយ៉ាងអយុត្តិធម៌ដោយសារបរិស្ថានមិនល្អ ហើយពួកគេនឹងមិនបន្តជួបផលប៉ះពាល់ទាំងនេះទៀត ដោយសារតែពួកគេរស់នៅជាប់នឹងតំបន់ឧស្សាហកម្ម?
3. សេដ្ឋកិច្ចរីកចម្រើនដែលមានស្ថេរភាព - តើមនុស្សទាំងអស់គ្នាដែលធ្វើការ រស់នៅនិងគោរពបូជានៅទីនេះ អាចបង្កើតការទំនាក់ទំនងគ្នាដោយរបៀបណារដើម្បីរក្សាមនុស្សគ្រប់ៗគ្នាដែលមានប្រវត្តិរស់នៅក្នុងតំបន់នេះកុំអោយពួកគេបាត់បង់ទីលំនៅរបស់ខ្លួន។

ក្នុងរយៈពេលបួនខែទៅមុខទៀត ក្រុម PCAT
បានដឹកនាំកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយដើម្បីធានាថា DVCBC
បានផ្តោតទៅលើសំលេងសហាគមន៍។
ពួកគេបានភ្ជាប់ទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធតាមលក្ខខណ្ឌរបស់ពួកគេដោយនាំយកការផ្សព្វផ្សាយទៅដល់ទីធ្លារបស់ពួកគេ។ ការប្រជុំ

ការធ្វើបទបង្ហាញនិងការសន្ទនាមួយទល់នឹងមួយតាមរយៈការបកប្រែភាសានិងសមស្របតាមវប្បធម៌ គឺជាមធ្យោបាយដែលក្រុម PCAT ស្វែងរកអោយបានយល់ថាតើសហគមន៍យល់យ៉ាងដែរអំពីការសហប្រត្តិបត្តការគ្នា។

សកម្មភាពផ្សព្វផ្សាយរួមមានការជិះទូកសម្បាន្តតាមស្ទឹងឌូវ៉មមីសដែលមានភាសាចំរុះជាច្រើន សហការគ្នាជាមួយកំពង់ផែក្រុងស៊ីឯថុល Seattle ។ ជាផ្នែកមួយនៃយុទ្ធសាស្ត្រផ្សព្វផ្សាយរបស់ខ្លួន ក្រុម PCAT បានជួយដឹកនាំអោយមានដំណើរកម្សាន្តតាមទូកដែលផ្តោតលើចំណុចសំខាន់ៗក្នុងតំបន់សហគមន៍ឌូវ៉មមីស DVCBC ។

នាពេលច្ចុប្បន្ននេះ ក្រុម PCAT និងកំពង់ផែក្រុងស៊ីឯថុលកំពុងសាងសងផែនការការងារមួយដែលនឹងដាក់អោយមានអាទិភាពមុនគេ ដែលបានចុះនៅក្នុង DVCBC ដើម្បីយកមកអនុវត្ត ។

ក្រុម PCAT ក៏នឹងធ្វើការលើច្បាប់ផងដែរ ពីព្រោះវានឹងចាប់ផ្តើមបង្កើតលទ្ធភាពបន្ថែមដើម្បីបម្រើសហគមន៍តទៅមុខទៀត។

លោកអ្នកអាចស្វែងយល់ពត៌មានបន្ថែមនៅខាងះ

ការវិភាគផលប៉ះពាល់សុខភាពកើនឡើងដងនៅក្នុងតំបន់ឌូវ៉មមីសនា ឆ្នាំ 2013
https://www.duwamishcleanup.org/chia

គំរោងសាកល្បងយុត្តិធម៌បរិស្ថានរបស់ US EPA TAG បង្កើតជាមូលដ្ឋានមួយដែលក្រោយមកក្លាយជាក្រុម PCAT៖
https://www.epa.gov/community-port-collaboration/pilot-projects-port-and-near-port-community-collaboration

ចលនាដើម្បីធ្វើអោយទៅជាផ្លូវការបង្កើតក្រុម PCAT 5/28:
https://www.portseattle.org/sites/default/files/2019-06/Motion%202019-07-%20Duwamish%20Equity%20Program.pdf

ដំណោះស្រាយមាត្រាលេខ 3767 ដែលបានធ្វើអោយក្រុម PCAT ទៅជាស្ថាប័នកំពង់ផែ 12/19:
https://www.portseattle.org/sites/default/files/2020-01/Resolution%203767%20with%20Exhibit.pdf

មតិដែលបានដាក់បញ្ចូលគ្នាដោយក្រុម PCAT បន្ទាប់ពីការអនុម័តលើដំណោះស្រាយមាត្រាលេខ 3767

https://iexaminer.org/coming-closer-the-duwamish-valley-community-benefits-from-commitment/

ដំណើររឿងកំពង់ផែស្តីពីការអនុម័តលើដំណោះស្រាយមាត្រាលេខ 3767
https://www.portseattle.org/news/port-seattle-expands-equity-program-duwamish-valley

តើដំណោះស្រាយមាត្រាលេខ **3767** គឺជាអ្វី?
កិច្ចសន្យាផ្តល់ផលប្រយោជន៍សហគមន៍ **(CBC)?**
សេចក្តីណែនាំគោលនយោបាយផ្តល់អត្ថប្រយោជន៍សហគមន៍តំបន់ស្ទឹងឌូវ៉មមីសមានគោលបំណងដើម្បីណែនាំការអនុវត្តកម្មវិធីសមធម៌សហគមន៍ឌូវសារីស (DVCEP) និងប្រតិបត្តិការកំពង់ផែផ្សេងទៀតដែលប៉ះទង្គិចដល់សហគមន៍តំបន់ស្ទឹងឌូវ៉មមីស។ ការលះបង់នេះ ជួយកំពង់ផែក្រុងស៊ីឯថុលធ្វើបេសកកម្មរបស់ខ្លួនដើម្បីធ្វើសេដ្ឋកិច្ចអោយរីកម្រើននិងមានគុណភាពជីវិតល្អនៅក្នុងតំបន់ដោយជំរុញអោយមានជំនួញ ទេសចរណ៍ ការងារ និងបង្កើតអោយមានការងារធ្វើប្រកបដោយសមធម៌ ទទួលខុសត្រូវនិងភាពរីករាយ។ ក្រុមសកម្មភាពសហគមន៍កំពង់ផែ (PCAT) សហការជាមួយគណៈកម្មាធិការប្រឹក្សាក្នុងតំបន់ ត្រូវធានាថា DVCEP សម្រេចបានគោលដៅចំនួនបីគឺ៖
**1**. ការកសាងសមត្ថភាពសហគមន៍និងកំពង់ផែសម្រាប់កិច្ចសហការគ្នាជាបន្តបន្ទាប់
**2**. សហគមន៍និងបរិស្ថានមានសុខភាពល្អ
**3.** សេដ្ឋកិច្ចរីកចម្រើនមានស្ថេរភាព

## ការសាងសងសមត្ថភាព

ស្របជាមួយនឹងគំនិតផ្តួចផ្តើមសមធម៌របស់កំពង់ផែដើម្បីដោះស្រាយការរើសអើងជាតិសាសន៍និងការទទួលស្គាល់ថាវិធីសាស្រ្តដែលមានប្រសិទ្ធភាពបំផុតសម្រាប់ការដោះស្រាយភាពមិនស្មើគ្នាគឺមកពីសហគមន៍ខ្លួនឯង, កម្មវិធី DVCEP នឹងកសាងសមត្ថភាពកំពង់ផែនិងសហគមន៍ដើម្បីធានាបាននូវការចូលរួមនិងភាពជាដៃគូប្រកបដោយអត្ថន័យនិងស្មើភាពគ្នា។ ដើម្បីសំរេចគោលដៅនេះ DVCEP នឹងជំរុញដល់ការសំរេចចិត្តរួមគ្នា គាំទ្រអ្នកដឹកនាំសហគមន៍ដែលមានស្រាប់និងនាពេលខាងមុខនិងសហការជាមួយសហគមន៍លើសកម្មភាពដែលជម្រុញអោយមានផលប្រយោជទៅវិញទៅមក។

តំបន់សកម្មភាពរបស់កំពង់ផែរួមមានទាំង ប៉ុន្តែមិនមានកំណត់ទេ:

- ការរួមចំណែក
- Tការហាត់ហ្វឹកហ្វឺននិងការអប់រំ

- សហាគមន៍
- ការចូលរួមជាមួយសហាគមន៍
- ការទទួលមតិពីសហាគមន៍
- កិច្ចសហប្រតិបត្តិការរបស់ទីភ្នាក់ងារអន្តរ
- អូសទាញយកលទ្ធផលពីទិន្នន័យ

## បរិស្ថាននិងសហាគមន៍មានសុខភាពល្អ

កំពង់ផែគឺទីកន្លែងដើម្បីដោះស្រាយយ៉ាងសកម្មនូវការប្រែប្រួលអាកាសធាតុនិងកត្តាបរិស្ថានដែលប៉ះពាល់ដល់សុខភាពសហគមន៍។ កម្មវិធី DVCEP នឹងលើកកម្ពស់ការចូលរួមរបស់សហាគមន៍លើសកម្មភាពនានាដែលឈានទៅរកលទ្ធផលដែលមានផលប្រយោជន៍ទៅវិញទៅមក។
តំបន់ប្រតិបត្តិការសម្រាប់កំពង់ផែរួមមានទាំង ប៉ុន្តែមិនមានកំណត់ទេ:

- ការប្រែប្រួលអាកាសធាតុ
- គុណភាពខ្យល់អាកាស
- ចរាចរណ៍ឡានដឹកទំនិញធំៗធ្វើដំណើរ
- សំឡេងដែលធ្វើអោយប៉ះពាល់
- សួនសាធារណៈនិងកន្លែងមានពណ៌បៃតង
- គុណភាពទឹក

## មានការរីកចំរើនផ្នែកសេដ្ឋកិច្ច

កំពង់ផែនឹងផ្សព្វផ្សាយពីយុទ្ធសាស្ត្រប្រឆាំងនឹងការបាត់បង់ទីលំនៅដែលជួយធ្វើឱ្យសហាគមន៍ក្នុងតំបន់ឌូវ៉មមីសមានភាពជឿនលឿនកើតឡើងតាមរយៈការហាត់ហ្វឹកហ្វឺនមានឱកាសជ្រើសរើសអាជីវកម្មនិងឱកាសសេដ្ឋកិច្ចដែលទាក់ទងទៅនឹងកំពង់ផែ។ DVCEP គួរតែលើកកម្ពស់កិច្ចសហាការជាក្រុមលើកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចដែលទទួលបាននូវផលប្រយោជន៍ទៅវិញទៅមក។
តំបន់ប្រតិបត្តិការសម្រាប់កំពង់ផែរួមមានទាំង ប៉ុន្តែមិនមានកំណត់ទេ:

- ការជ្រើសរើសនិងការរក្សាទុក
- ការអភិវឌ្ឍកម្លាំងពលកម្មយុវជន
- ការអភិវឌ្ឍកម្លាំងពលកម្មមនុស្សពេញវ័យ
- ការអភិវឌ្ឍសេដ្ឋកិច្ច
- គាំទ្រសេដ្ឋកិច្ចប្រកបដោយសមធម៌ចម្រុះនិងសុវត្ថិភាព

មើលដំណោះស្រាយលេខ 3767:
ការប្តេជ្ញាចិត្តលើអត្ថប្រយោជន៍សហាគមន៍ទាំងស្រុង:
English

[Spanish]
[Khmer]
[Vietnamese]

## ហេតុអ្វីកិច្ចការនេះមានសារៈសំខាន់

ក្នុងតំបន់ឌូវ៉ាមមីស ជាយូរអង្វែងមកហើយ ត្រូវបានគេហៅថា ជាសហាគមន៍មួយដែលមានភាពអយុត្តិធម៌ខាងបរិស្ថាន ជាសហាគមន៍ដែលបន្ទុកនូវសុខភាពនិងហានិភ័យបរិស្ថានខ្ពស់និងផលប៉ះពាល់បរិស្ថានវិជ្ជមានតិចជាងក្នុងតំបន់ក្រុងស៊ីងថុល។ តំបន់រស់នៅជាប់មាត់ស្ទឹងឌូវ៉ាមមីស គឺសៅផាក South Park និងជចថោន Georgetown ដែលជាទីកន្លែងបណ្ដាលអោយប៉ះពាល់ខ្លាំងដល់ប្រជាជនរស់នៅទីនោះ ដោយសារជាទីកន្លែងមានសារធាតុកខ្វក់ ដែលអាចធ្វើអោយប្រជាជនជួបប្រទះនិងសារជាតិពុលនៅតាមឆ្នេរស្ទឹង ហែលទឹកឬពេលពួកគេដើរក្នុងទឹកនិងពីការនេសាទត្រី។ សៅផាក South Park និងជចថោន Georgetown គឺជាទីកន្លែងមួយដែលប្រជាជនមានប្រាក់ចំណូលទាបបំផុតក្នុងចំណោមតំបន់នៅក្នុងក្រុងស៊ីងថុល ហើយជាពិសេស សៅផាក South Park គឺជាភូមិមួយដែលមានប្រជាជនចម្រុះជាតិសាសន៍ច្រើនបំផុតរស់នៅទីនោះ។ លើសពីនេះទៅទៀត ពួកគេ ក្នុងប្រវត្តិសាស្រ្ត មានការខ្វះខាតនិងខ្វះការជះឥទ្ធិពលលើអ្នកធ្វើសេចក្ដីសម្រេចចិត្តដែលកំណត់អនាគតសហាគមន៍របស់ពួកគេមិនដូចសហាគមន៍ដទៃទៀតដែលមានឥទ្ធិពលច្រើននៅក្នុងតំបន់។

អាយុកាលរបស់អ្នករស់នៅក្នុងតំបន់ឌូវ៉ាមមីស ជាមធ្យម មានអាយុកាល 8 ឆ្នាំ ខ្លីជាងអ្នករស់នៅក្នុងទីក្រុងស៊ីងថុលនិងតំបន់ឃីងខោនធី។ លើសពីនេះទៅទៀត ការរស់នៅក្នុងទីកន្លែងដែលមានទំហំផ្ទៃក្រឡាត្រឹមតែ 40 ហ្វីតការ៉េក្នុងមួយនាក់ប្រៀបធៀបទៅនឹងផ្ទៃដីមានទំហំមធ្យម 387 ហ្វីតការ៉េក្នុងមួយនាក់នៅក្នុងដែនកំណត់ទីក្រុងស៊ីងថុលនិងបរិយាកាសកខ្វក់ជាច្រើនចេញមកពីតំបន់ឧស្សាហកម្ម រួមទាំងនៅតាមមហាវិថីសំខាន់ៗជុំវិញ (ដូចជា ផ្លូវហាយវេ 99 និងផ្លូវជាតិលេខ 509 និងផ្លូវជាតិលេខ 5 ។ កត្តាទាំងនេះរួមបញ្ចូលគ្នាដើម្បីធ្វើអោយសហាគមន៍ដែលប្រឈមនឹងបញ្ហាសុខភាពនិងសុវត្ថិភាពសាធារណៈនិងភាពខុសគ្នាផ្នែកសេដ្ឋកិច្ចដែលត្រូវការការគាំទ្រពីសហាគមន៍និងកែសម្រួលប្រព័ន្ធវិនិយោគជាលក្ខណៈសហាគមន៍។

## សូមទាក់ទងយើង៖

FB [Duwamish Valley Port Community Action Team]

IG Duwamish Valley Port Community Action Team